

**ឈ្មោះ :** ណាំ ស៊ូទាង

**ប្រភេទអាហាររូបករណ៍:** អាហារូបករណ៍របស់រដ្ឋាភិបាលជប៉ុន(២០០០)

**វិទ្យាស្ថានដែលទទួលពាក្យរបស់បេក្ខជន:**

Kansai Gakuyukai Nihongo Gakko and Sundai Gaigo & Kanko Senmong Gakko

**មុខរបរបច្ចុប្បន្ន:** បុគ្គលិកនៃមជ្ឈមណ្ឌល សហប្រតិបត្តការកម្ពុជា-ជប៉ុន (CJCC)

1. មូលហេតុអ្វីបានជាអ្នកដាក់ពាក្យចូលរួមក្នុងអាហារូបករណ៍របស់រដ្ឋាភិបាលជប៉ុន?

នាងខ្ញុំមានមូលហេតុ៣ដែលញ៉ាំងឲ្យនាងខ្ញុំបានដាក់ពាក្យចូលរួមក្នុងអាហារូបករណ៍របស់រដ្ឋាភិបាលជប៉ុន។ ជាតំបូង ដូចដែលអ្នកទាំងអស់គ្នាដឹងស្រាប់ថាប្រទេសជាតិយើងត្រូវការជាចាំបាច់នូវធនធានមនុស្សដើម្បីអភិវឌ្ឍនប្រទេសក្រោយសង្រ្គាមស៊ីវិលដែលមានរយៈពេលជាង៣ទស្សវត្ស។នាងខ្ញុំពិតជាមានបំណងចង់ចូលរួមក្នុងការកសាងជាតិសាសន៍ឡើងវិញណាស់។ ចំនុចទី២ ការទទួលបានអាហារូបករណ៍របស់រដ្ឋាភិបាលជប៉ុនគឺកិត្តយសដ៏ប្រពៃសំរាប់សិស្សនិងនិសិត្សនាសម័យកាលនោះ។ពីព្រោះអ្នកដែលប្រលងជាប់គឺត្រូវបានគេគិតថាជាអ្នកខ្លាំងពិតៗ។ ជាចុងក្រោយនាងខ្ញុំគិតថា ការទៅរៀននៅប្រទេសជប៉ុនគឺជាឱកាសដ៏ល្អមួយសំរាប់នាងខ្ញុំរៀនអំពីជីវិតនិងការផ្សងព្រេងមួយដែលមិនធ្លាប់មានសំរាប់នាងខ្ញុំផ្ទាល់៕

2. តើការសិក្សារបស់អ្នកនៅប្រទេសជប៉ុនយ៉ាងម៉េចដែរ?

នាងខ្ញុំបានរៀនជំនាញជាច្រើនដូចជា ភាសាជប៉ុន មគ្គុទេសក៍ទេសចរណ៍ សេដ្ឋកិច្ច និងអភិវឌ្ឍអន្តរជាតិផ្នែកអភិវឌ្ឍន៍ជនបទ។ នាងខ្ញុំមានចំណាប់អារម្មណ៍ពិសេសលើការអភិវឌ្ឍប្រទេសជប៉ុនបន្ទាប់ពីសង្រ្គាមលោកលើកទី២ ដែលអាចធ្វើខ្លួនគេឲ្យក្លាយជាមហាអំណាចសេដ្ឋកិច្ចដូចសព្វថ្ងៃនេះ។ ការរៀននៅក្នុងសាលាជាទូទៅគឺគេផ្តោតធ្ងន់ទៅលើការសិក្សាស្រាវជ្រាវរៀនដោយខ្លួនឯង ក្រៅពីការស្តាប់គ្រូនៅក្នុងថ្នាក់រៀន។ ក្រៅពីនេះនាងខ្ញុំបានរៀនពីសង្គមជប៉ុនដោយផ្ទាល់ដូចជាការស្តាប់ពីការអភិវឌ្ឍប្រទេសជប៉ុនតាមរយៈការតំណាលរបស់អ្នកស្រុក ប្រវត្តិសាស្រ្ត ទំនាមទំលាប់ និងផ្នត់គំនិតរបស់ប្រជាជនជប៉ុនទៀតផង។ វាគឺជាឱកាសដ៏កំរសំរាប់នាងខ្ញុំក្នុងជិវិតដែលបានទទួលឱកាសសិក្សាទាំងចំណេះវិជ្ជានិង ការហាត់ពត់លត់ដំខ្លួនបែបនេះ៕

3. តើការរស់នៅរបស់អ្នកនៅប្រទេសកម្ពុជាមានស្ថានភាពយ៉ាងម៉េចដែរ?

តំបូងគោលបំណងចំបងក្នុងការទៅសិក្សានៅជប៉ុនគឺ ដើម្បីទៅរៀនពីជប៉ុនសំរាប់អភិវឌ្ឍនប្រទេសកម្ពុជា។ ឥឡូវនេះវាជាពេលវេលាដែលនាងខ្ញុំអាចប្រើចំណេះដឹងសំរាប់ជួយអភិវឌ្ឍនប្រទេសជាតិ ស្របពេលជាមួយនឹងការរីកចំរើនសេដ្ឋកិច្ចនិងតំណាក់កាលអភិវឌ្ឍនប្រទេសជាតិ ។

នាងខ្ញុំអាចប្រើទាំងចំណេះដឹងនិងបទពិសោធន៏ដែលទទួលបានពីជប៉ុនយកមកធ្វើការនៅ CJCC បានត្រូវជំនាញយ៉ាងល្អ ដែលសំដៅពង្រឹងទំនាក់ទំនងរវាងខ្មែរនិងជប៉ុននិងការអភិវឌ្ឍប្រទេសកម្ពុជា៕

4. សាររបស់បេក្ខជនអាហារូបករណ៍សម្រាប់ឆ្នាំនេះ។

ទោះបីជាពេលបច្ចុប្បន្ននេះ យើងមានឱកាសច្រើនជាងមុនក្នុងការដាក់ពាក្យទៅរៀននៅបរទេសដូចជា អាមេរិចកាំង អូស្រ្តាលី អឺរ៉ុប ជាដើមក៏ដោយ ក៏ការទៅសិក្សានៅជប៉ុននៅតែផ្តល់ឲ្យអ្នកទាំងអស់គ្នានូវអ្វីជាច្រើនទៀត។ ការស្រាវជ្រាវខាងផ្នែកវិទ្យាសាស្រ្តធម្មជាតិនិងបច្ចេកវិទ្យារបស់ប្រទេសជប៉ុននៅតែឈរក្នុងលំដាប់ជួរមុខគេក្នុងពិភពលោក។ ចំណេះដឹងទាំងអស់នេះគឺជាមូលដ្ឋានគ្រឹះក្នុងការសាងកម្ពុជាឆ្ពោះទៅកាន់ឧស្សាហូបនីយកម្ម ក្នុងពេលអនាគត់។ ប្រសិនបើយើងរៀនពីជប៉ុនបានកាន់តែច្រើន គឺមានន័យថា

យើងអាចរំដោះខ្លួនយើងឲ្យចាកចេញពីសំណាញ់នៃភាពក្រីក្រ និងពង្រឹងសេដ្ឋកិច្ចរបស់ប្រទេសយើងឲ្យកាន់តែរីកចំរើន។សូមប្អូនៗទាំងអស់គ្នាព្យាយាមចាប់ឱកាសទៅរៀននៅជប៉ុនជាមួយនិងអាហារូបករណ៍សម្រាប់ឆ្នាំឲ្យបាន។

សំរាប់ទស្សនៈផ្ទាល់ខ្លួន “រៀនបានកាន់តែច្រើននៅពីក្មេង គឺកាន់តែល្អ” ជាពិសេសប្អូនៗស្ត្រី។ អ្វីដែលប្អូនៗបានរៀននិងលត់ដំខ្លួននៅជប៉ុន និងក្លាយជាពុទ្ធិ បទពិសោធន៍ និងបណ្តាញសង្គមសំរាប់ប្អូនៗនៅពេលអនាគត់ ពេលប្អូនៗចាប់ផ្តើមធ្វើការងារ៕